# មេរៀនទី ១២៥៖ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

ម៉ាថាយ ២៧៖២៧-៥៦; ២៨៖១-១០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/J3YWxmU86OU

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/sw73Qh1i6yQ

**គោលបំណង៖** ព្រះយេស៊ូវរស់ឡើងវិញ។

**ខគម្ពីរចងចាំ៖ ១កូរិនថូស ១៥៖១៧** *"ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្ដីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះគ្រីស្ទទ្រង់រស់ https://youtu.be/kzg10u5bil4

២.នៅរស់ https://youtu.be/NGQXTg3Uogg

៣.ព្រះគ្រីស្ទទ្រង់រស់ឡើងវិញ https://youtu.be/WTL3xf69YEY

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** «ទេវតានៃព្រះ»




សម្ភារៈដែលត្រូវការ៖ ក្រមា ពីរ ឬបី

១. ចែកកុមារជាពីក្រុមស្មើគ្នា

២. ក្រុមទាំងពីរត្រូវរើសតំណាងក្រុមម្នាក់មួយមកប៉ាវ ក្រុមណាប៉ាវឈ្នះ ក្រុមនោះត្រូវ អង្គុយចុះដោយដើរតួ ជាម៉ារាព្រមទាំងយំ និង បិតភ្នែកផង

៣. ហើយក្រុមប៉ាវចាញ់ត្រូវនាំកូនក្រុមរបស់ខ្លួនចេញក្រៅថ្នាក់ ពួកគេ ត្រូវជ្រើសរើសកុមារណាម្នាក់ធ្វើជាទេវតា




៤. កុមារដែលតំណាងឲ្យទេវតានោះត្រូវដើរចូលមកក្នុងថ្នាក់វិញ ដោយរុំក្រមាឲ្យជិត រួចនិយាយពាក្យថា "ម៉ារាអើយកុំខ្លាចឡើយ!" ហើយត្រូវឡប់ទៅក្រៅថ្នាក់វិញ។

៥. បន្ទាប់មកគ្រូសួរក្រុមរបស់ម៉ារាថា តើកុមារម្នាក់នោះជានរណា? ប្រសិនបើពួកគេទាយត្រូវក្រុមរបស់ ពួកគេនឹងទ ទួល បានមួយពិន្ទុ តែបើទាយខុសក្រុមដែលដើរតួជាទេវតាជាអ្នកដែលទទួលបានមួយពិន្ទុ នោះវិញ។ បន្ទាប់មក ឲ្យក្រុមដែលដើរតួជាម៉ារានោះ ដើរតួជាទេវតាវិញម្តង។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មិនថានៅពេលដែលយើងក្រៀមក្រំ ឬក៏ចុះខ្សោយក៏ដោយ ព្រះយេស៊ូវគឺតែងតែគង់នៅជាមួយពួកយើង ពីព្រោះព្រះយេស៊ូវទ្រង់រស់ឡើងវិញ!

**៤. ការណែនាំមេរៀន**

តើនៅក្នុងជីវិតរបស់អ្នកតើមាននរណាម្នាក់ដែលហ៊ានស្លាប់ជំនួសអ្នកបានដែរឬទេ? តើឪពុកម្តាយរបស់អ្នកនឹងស្លាប់ដើម្បីសង្គ្រោះអ្នកដែរឬទេ? តើបងប្អូនប្រុសស្រី ឬក៏មិត្តភក្តិរបស់អ្នកអាចស្លាប់ដើម្បីសង្គ្រោះ

អ្នកដែរឬទេ? នៅទីនេះគឺមានមនុស្សម្នាក់ហ៊ានស្លាប់ដើម្បីសង្គ្រោះអ្នក ហើយទ្រង់មានឈ្មោះថា ព្រះយេស៊ូវ។ ប៉ុន្តែបើទ្រង់បានស្លាប់ ហើយស្លាប់ជារៀងរហូតនោះ នោះគឺជាបញ្ហាដ៏ធំសម្រាប់យើង។ ហើយនោះគឺគ្មាន សេចក្តីសង្ឃឹមទេនៅក្នុងជីវិត-ហើយជាពិសេសនោះគឺជីវិតនៅឯនគរស្ថានសួគ៌ជាមួយព្រះ។ ថ្ងៃនេះយើង នឹងរៀនពីការយាងត្រឡប់មករស់ឡើងវិញរបស់ព្រះយេស៊ូវ ដើម្បីបញ្ជាក់ថាទ្រង់ពិតជាបានសង្គ្រោះពួកយើងពិតមែន។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅរសៀលថ្ងៃមួយប្រហែលកាលពី ២០០០ឆ្នាំមុន ព្រះយេស៊ូវត្រូវបានចាប់ខ្លួនដោយទាហានរបស់រ៉ូម ហើយពួកសិស្សបានឈរមើលនៅពេលដែលទាហានរបស់រ៉ូមធ្វើបាបព្រះយេស៊ូវ។ ព្រះយេស៊ូវត្រូវបានគេវាយស្ទើតែស្លាប់ទៅហើយ ថែមទាំងចំអក និងឲ្យទ្រង់លីឈើឆ្កាងរបស់ព្រះអង្គទៅកន្លែងដែលពួកគេត្រូវឆ្កាងទ្រង់ទៀតផង។ នៅឯគាល់កូថា ព្រះយេស៊ូវត្រូវបានគេឆ្កាងដោយដំដែកគោលឲ្យស្លាប់នៅចន្លោះ ចោរពីរនាក់ ដែលជាឧក្រិដ្ឋជនផងដែរ។ វាគឺបានធ្វើឲ្យព្រះយេស៊ូវមានការឈឺចាប់ជាខ្លាំង ហើយទ្រង់ក៏បានសុគត់ទៅ មានមិត្តភក្តិរបស់ទ្រង់បានយកសពរបស់ព្រះអង្គទៅបញ្ចុះទៅក្នុងរូងមួយ ដែលគេហៅថាផ្នូរ ហើយបានដាក់ថ្មដ៏ធំមួយនៅពីមុខរូងនោះ។

បីថ្ងៃក្រោយមកបន្ទាប់ពីព្រះយេស៊ូវបានសុគត់រួច ម៉ារាម៉ាដាឡា និងម៉ារាម្នាក់ទៀត បានទៅផ្នូរដែលជាកន្លែងបញ្ចុះសពរបស់ព្រះយេស៊ូវ។ ពួកគេចង់ទៅមើលកន្លែងដែលព្រះយេស៊ូវត្រូវបានគេបញ្ចុះ។ នៅពេលដែលពួកគេបានទៅដល់ទីនោះក៏មានការរញ្ជួយដីដ៏ខ្លាំងមួយបានកើតឡើង។

ការរញ្ជួយដីនោះកើតឡើងដោយសារតែទេវតានៃព្រះបានចុះមកពីស្ថានសួគ៌។ ទេវតាបានរំកិលថ្មដែលបានបាំងផ្លូវចូលទៅឯកន្លែងបញ្ចុះសពព្រះយេស៊ូវនោះចេញ។ ទេវតាបានអង្គុយនៅលើផ្ទាំងថ្មដ៏ធំនោះ។ ទេវតាក៏បាននិយាយទៅកាន់ស្ត្រីទាំងពីរនាក់នោះថា ព្រះគម្ពីរ **ម៉ាថាយ ២៨៖៥-៧** "កុំឲ្យភ័យអី ដ្បិតខ្ញុំដឹង ហើយថា នាងរកព្រះយេស៊ូវដែលត្រូវឆ្កាង។ តែទ្រង់មិនគង់នៅទីនេះទេ ដ្បិតទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយ ដូចជាទ្រង់បានមានព្រះបន្ទូលទុក។ ចូរមកមើលកន្លែងដែលទ្រង់បានផ្ទំចុះ។ រួចទៅឲ្យឆាប់ប្រាប់ ដល់ពួកសិស្សទ្រង់ថា ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ មើលទ្រង់យាងទៅឯស្រុកកាលីឡេ មុនអ្នករាល់គ្នា។ នឹងឃើញទ្រង់នៅស្រុកនោះ នែ ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ។"

បន្ទាប់មកពួកស្ត្រីទាំងនោះក៏បានប្រញាប់ទៅប្រាប់ពួកសិស្សពីអ្វីដែលខ្លួនបានឃើញ។ ពួកគេគឺពោរពេញដោយសេចក្តីអំណរ។ នៅតាមផ្លូវត្រឡប់ទៅវិញពួកគេក៏បានជួបជាមួយព្រះយេស៊ូវ។ ហើយក៏បានលុតជង្គង់នៅព្រះបាតទា និងថ្វាយបង្គំទ្រង់។ **ម៉ាថាយ ២៨៖១០** "នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅនាង ថា កុំខ្លាចអី ចូរទៅប្រាប់ដល់បងប្អូនខ្ញុំផង ឲ្យគេទៅឯស្រុកកាលីឡេទៅ គេនឹងឃើញខ្ញុំនៅស្រុកនោះ ហើយ។"

ម៉ារាទាំងពីរគិតថា ព្រះយេស៊ូវគួរតែបញ្ចុះនៅក្នុងផ្នូរ។ ប៉ុន្តែអត់ទេ។ ទេវតាបានប្រាប់ពួកគេថា ព្រះយេស៊ូវត្រឡប់មកមានព្រះជន្មរស់ឡើងវិញ។ហើយម៉ារាទាំងពីរក៏បានឃើញព្រះយេស៊ូវផ្ទាល់ភ្នែករបស់ពួកគេដែរ ។ពួកគេគឺមានការរំភើបនិងពេញដោយអំណរ ដោយសារតែមិត្តភក្តិដ៏ល្អរបស់ពួកគេគឺព្រះយេស៊ូវ នៅមានព្រះជន្មនោះ។

ព្រះយេស៊ូវសុគត់ហើយមានព្រះជន្មរស់ឡើងវិញ គឺជាផ្នែកមួយដ៏មានសារៈសំខាន់ សម្រាប់សេចក្តីជំនឿរបស់គ្រីស្ទបរិស័ទយើង។ ពីព្រោះព្រះយេស៊ូវបានត្រឡប់មកមានជីវិតរស់ឡើងវិញ ហើយទ្រង់អាចបង្ហាញពីផ្លូវដែលយើងអាចទៅឯព្រះបាន។ ព្រះយេស៊ូវបានអត់ទោសរាល់អំពើបាបរបស់យើង ហើយបាននាំ

យើងទៅឯព្រះ។ ដោយសារតែព្រះយេស៊ូវយើងអាចធ្វើជាមិត្តជាមួយព្រះបាន។ ពួកយើងត្រូវតែខំឲ្យអស់ពីសមត្ថភាពដែលយើងអាចធ្វើបាន ដើម្បីចងចាំពីសារៈសំខាន់នៃការសុគត់របស់ព្រះយេស៊ូវ និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ ហើយអរព្រះគុណទ្រង់សម្រាប់ការទាំងអស់នោះ។

## ៦. សំនួរពិភាក្សា

១. តើមានរឿងអ្វីកើតឡើងចំពោះព្រះយេស៊ូវមុនពេលដែលទ្រង់សុគត់នៅលើឈើឆ្កាង?
*(ព្រះយេស៊ូវត្រូវបានគេ វាយស្ទើតែស្លាប់ ថែមទាំងចំអក និងឲ្យទ្រង់លីឈើឆ្កា ងរបស់ព្រះអង្គទៅកន្លែងដែលពួកគេត្រូវ ឆ្កាងទ្រង់ទៀតផង)*

២. តើមានរឿងអ្វីកើតឡើងបន្ទាប់ពីទ្រង់បានសុគត់និងបញ្ចុះទៅក្នុងផ្នូរ?
*(ទ្រង់មានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី)*

៣. តើមនុស្សដំបូងគេដែលបានដឹងថាព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញគឺជានរណា? *(ស្ត្រីៗ)*

៤. ហេតុអ្វីបានជាការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវមានសារៈសំខាន់សម្រាប់គ្រីស្ទបរិស័ទ?
*(ព្រះយេស៊ូវបានសងថ្លៃអំពើបាបរបស់យើង ព្រះយេស៊ូវអាចយកឈ្នះសេចក្តីស្លាប់ ហើយឥឡូវនេះ យើងមានសេចក្តីសង្ឃឹមដែលអាចរស់នៅជាមួយព្រះបានជារៀងរហូត)*

## ៧. ល្បែងកំសាន្ត “ព្រះយេស៊ូវរស់ឡើងវិញ”



១. ចែកកុមារជាក្រុមដែលមួយក្រុមមានគ្នា ប្រាំនាក់
២. ក្រុមនីមួយៗត្រូវសំដែងពីការសុគត់ និងរស់ឡើងវិញរបស់ព្រះយេស៊ូវ
៣. សម្តែងម្តងមួយក្រុម ឲ្យកុមារគ្រប់ក្រុមពិភាក្សាគ្នាពីការសម្តែងនោះដោយខ្លួនឯង
៤. ក្រុមណាដែលសម្តែងបានល្អជាងគេក្រុមនោះជាអ្នកឈ្នះ។

## ៨. ខគម្ពីរចងចាំ

**១កូរិនថូស ១៥៖១៧** *“ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្តីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ ។”*

## ៩. ហាត្ថកម្ម «ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ»



សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត
១. ផាត់ពណ៌រូបភាព ផ្នូរ ដុំថ្ម ទេវតា និងរូបព្រះយេស៊ូវ ហើយកាត់វាចេញមក។
២. បិតរូបព្រះយេស៊ូវជាមួយផ្នូរ និងបិតរូបដុំថ្មនៅពីក្រៅ។បិតរូបទេវតានៅពីលើផ្នូរនោះ។
៣. នៅពេលដែលអ្នកបើក ដុំថ្មអ្នកនឹងឃើញព្រះយេស៊ូវមានព្រះជន្មរស់នៅក្នុង នោះ!

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ការរស់ឡើងវិញរបស់ព្រះយេស៊ូវបានបញ្ជាក់ពីជីវិតអស់កល្បរបស់យើង។ ដោយសារទ្រង់បានស្លាប់ ហើយត្រលប់មករកយើងវិញ នោះព្រះនឹងអត់ទោសបាបរបស់យើង ហើយយើងអាចរស់នៅជារៀងរហូតក្នុងទំនាក់ទំនងជាមួយព្រះយេស៊ូវ។ តើពេលណាជាពេលចុងក្រោយដែលអ្នកដោះស្រាយស្ថានការណ៍លំបាក ឬមានអារម្មណ៍បាក់ទឹកចិត្ត? សូមរំឭកខ្លួនអ្នកអំពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ និងអំណោយនៃជីវិតអស់កល្បជានិច្ច។ តើការរំពឹងគិតអំពីព្រះយេស៊ូវបានដាក់ស្ថានភាពនោះក្នុងទស្សនៈនិងជួយអ្នកដោះស្រាយវាយ៉ាងដូចម្តេច? សូមប្តេជ្ញាបន្តស្វែងរកការរស់ឡើងវិញរបស់ព្រះយេស៊ូវ ហើយស្វែងយល់ពីរបៀបដែលវានៅតែផ្លាស់ប្តូរអ្នក។ អរគុណព្រះយេស៊ូវ សម្រាប់ជ័យជំនះដ៏មិនគួរឱ្យជឿរបស់ព្រះអង្គ!

# ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

១.ផាត់ពណ៌រូបភាព ផ្នូរ ដុំថ្ម ទេវតា និងរូបព្រះយេស៊ូវ ហើយកាត់វាចេញមក។

២. បិតរូបព្រះយេស៊ូវជាមួយផ្នូរ និងបិតរូបដុំថ្មនៅពីក្រៅ។បិតរូបទេវតានៅពីលើផ្នូរនោះ។

៣. នៅពេលដែលអ្នកបើកដុំថ្ម អ្នកនឹងឃើញព្រះយេស៊ូវមានព្រះជន្មរស់នៅក្នុងនោះ!



# ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

១.ផាត់ពណ៌រូបភាព ផ្នូរ ដុំថ្ម ទេវតា និងរូបព្រះយេស៊ូវ ហើយកាត់វាចេញមក។

២. បិតរូបព្រះយេស៊ូវជាមួយផ្នូរ និងបិតរូបដុំថ្មនៅពីក្រៅ។បិតរូបទេវតានៅពីលើផ្នូរនោះ។

៣. នៅពេលដែលអ្នកបើកដុំថ្ម អ្នកនឹងឃើញព្រះយេស៊ូវមានព្រះជន្មរស់នៅក្នុងនោះ!

